# មេរៀនទី ៥២: ជនជាតិអ៊ីស្រាអែលចាកចេញពីអេស៊ីព្ទ

## និក្ខមនំ ១១:១-១២:៣៦

**គោលបំណង៖** សេរីភាពរបស់ព្រះស្ថិតស្ថេរជារៀងរហូតសម្រាប់យើង។

**ខគម្ពីរចងចាំ៖ យ៉ូហាន ៨:៣៦** *"ដូច្នេះបើព្រះរាជបុត្រាប្រោសឲ្យអ្នករាល់គ្នាបានរួច នោះនឹងបានរួចជាពិត។"*

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**

យើងទាំងអស់គ្នាត្រូវបានចងជាប់ដោយអំពើបាបរហូតដល់ព្រះបានដោះលែងយើងឲ្យមានសេរីភាព។ ដោយសារព្រះយេស៊ូវយើងមានជីវិតថ្មី ហើយយើងកាន់តែខិតជិតទ្រង់ជារៀងរាល់ថ្ងៃ។ រឿងក្នុងព្រះគម្ពីរនៅក្នុងមេរៀននៅថ្ងៃនេះជាសាច់រឿងរបស់យើង។ ពីមុនយើងជាទាសករនៃអំពើបាប ហើយយើងរស់នៅក្នុងភាពងងឹត តែពេលនេះព្រះលោហិតរបស់ព្រះយេស៊ូវបានការពារយើងចេញពីសេចក្ដីស្លាប់ ហើយធានាឱ្យយើងមានជីវិតអស់កល្បជានិច្ច។ សូមអធិស្ឋាន៖ "អរព្រះគុណព្រះយេស៊ូវ ចំពោះការលះបង់របស់ទ្រង់ដើម្បីសេរីភាព និងជីវិតរបស់កូន"។

**ចំរៀង៖** ១. បាបខ្ញុំរួចអស់ហើយ ២.ព្រះយើងជាព្រះអស្ចារ្យ ៣. ក្នុងព្រះនាមព្រះយេស៊ូវ

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**៣. ល្បែងកំសាន្ត «អន្ទាក់»**



១. ជ្រើសរើសកុមារប្រហែល៥ទៅ៦នាក់ ហើយឲ្យពួកគេឈរជារង្វង់ និង កាន់ដៃគ្នា។

២. រើសកុមារម្នាក់ឲ្យឈរនៅចំកណ្ដាលរង្វង់នោះ។

៣. គោលបំណងនៃល្បែងនេះគឺធ្វើយ៉ាងណាឃាំងកុមារដែលឈរនៅចំកណ្ដាលរង្វង់នោះមិនឲ្យគេចខ្លួនចេញក្រៅរង្វង់បាន។

៤.បន្ទាប់ពីលេងល្បែងចប់សូមសួរកុមារថា៖ តើប្អូនមានអារម្មណ៍បែបណាដែលត្រូវជាប់ក្នុងអន្ទាក់ដូចនេះ? តើប្អូនគិតថាត្រូវធ្វើអ្វីនៅពេលនៅពេលដែលប្អូនជាប់ក្នុងរង្វង់នេះ?(បើនៅមានពេលសូមលេងម្ដងទៀត)។

**៤. ការណែនាំមេរៀន**

ថ្ងៃនេះ យើងនឹងរៀនពីការដែលព្រះបានរំដោះជនជាតិអ៊ីស្រាអែលចេញពីប្រទេសអេស៊ីព្ទ។ យើងមិនធ្លាប់រស់នៅជាទាសករ ដូច្នេះយើងមិនដែលគិតថាយើងត្រូវការសេរីភាពនោះទេ។ ពេលខ្លះមនុស្សរងនូវភាពអយុត្តិធម៌ និងទុក្ខវេទនាពីអ្នកដែលមានអំណាច។ ទោះបីជាសង្គមសព្វថ្ងៃនេះមានមនុស្សមួយចំនួនទទួលរងការជិះជាន់ពីអ្នកមានអំណាចយ៉ាងណាក៏ដោយ។ ប៉ុន្តែអំពើបាប ការព្រួយបារម្ភ និងភាពភ័យខ្លាចទាំងនោះ គឺជាអ្វីដែលរាំងយើងមិនឲ្យមានសេរីភាព។ អំពើបាបបានធ្វើឲ្យយើងមិនសប្បាយចិត្ត កើតទុក្ខ និងព្រួយបារម្ភ។ ពេលខ្លះយើងគិតថាអំពើបាបតូចមួយដូចជា ការនិយាកុហក គឺវាមិនធំដុំអីនោះទេ ប៉ុន្តែការដែលចាប់ផ្ដើមនិយាយកុហកតូច

មួយនឹងនាំយើងទៅរកការកុហកម្ដងហើយម្ដងទៀត។ ហើយមិនយូរមិនឆាប់នឹងធ្វើឲ្យយើងជាប់ជំពាក់នឹងការកុហកនោះ។ យើងអាចនឹងមានអារម្មណ៍ថាគ្មាននរណានឹងអាចរំដោះយើងចេញពីការកុហកទាំងអស់នោះបានទេ ប៉ុន្តែព្រះនឹងអត់ទោស ហើយរំដោះយើងចេញបាននៅពេលដែលយើងនិយាយពាក្យថា "សុំទោស" ព្រះអង្គនឹងធ្វើឲ្យយើងមានអារម្មណ៍ស្រស់ស្រាយឡើងវិញ។ ចូរយើងស្វែងយល់ពីរបៀបដែលព្រះបានរំដោះជនជាតិអ៊ីស្រាអែលចេញពីអេស៊ីព្ទ!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ជាយូរលង់ណាស់មកហើយ ជនជាតិអ៊ីស្រាអែលដែលជារាស្ត្ររបស់ព្រះបានជាប់នៅអេស៊ីព្ទដែលស្ថិតនៅក្រោមការគ្រប់គ្រងដ៏អាក្រក់របស់ស្ដេចផារ៉ោន។ ផារ៉ោនបានឲ្យជនជាតិអ៊ីស្រាអែលធ្វើការងារជាទាសកអស់រយៈពេលជាង **៤០០ឆ្នាំ**។ រាស្ត្ររបស់ព្រះបានស្រែករកជំនួយ ហើយនៅទីបំផុតព្រះបានឆ្លើយតបនឹងពួកគេ! ព្រះបានចាត់ម៉ូសេឲ្យទៅរំដោះរាស្ត្ររបស់ព្រះអង្គ។ ទ្រង់បានធ្វើឲ្យមានគ្រោះកាចចំនួន ៩ មកលើជនជាតិអេស៊ីព្ទ ប៉ុន្តែផារ៉ោននៅតែមិនអនុញ្ញាតឱ្យជនជាតិអ៊ីស្រាអែលចេញទៅ។

ចុងក្រោយ ព្រះបានបង្កើតគ្រោះកាចទី១០ដែលជាគ្រោះកាចខ្លាំងជាងគេបំផុត។ ព្រះបានមានបន្ទូលថា កូនប្រុសច្បងនៃគ្រួសារនីមួយៗដែលមិនស្ដាប់តាមបង្គាប់ទ្រង់នឹងត្រូវស្លាប់។ ស្ដេចផារ៉ោន និង ជនជាតិអេស៊ីព្ទភាគច្រើនមិនជឿលើអ្វីដែលម៉ូសេបាននិយាយទេ។ ព្រះមានផែនការការពាររាស្ត្ររបស់ទ្រង់និងអ្នកណាដែលជឿដល់ទ្រង់។ ព្រះអង្គបានប្រាប់ម៉ូសេឱ្យគ្រួសារនីមួយៗសំលាប់កូនចៀមដ៏ល្អឥតខ្ចោះមួយ ហើយយកឈាមទៅលាបនៅក្របទ្វារទាំងសងខាង ហើយលើធ្នឹមទ្វារផ្ទះរបស់ពួកគេផង។

គ្រោះកាចនឹងរំលងផុតផ្ទះណាបានលាបឈាមនោះ ហើយផ្ទះទាំងនោះនឹងមិនមានគ្រោះកាចមកយាយីឡើយ កូនចៀមដែលគ្មានកំហុសបានស្លាប់ ដូច្នេះអ៊ីស្រាអែលត្រូវបានការពារ និង ជួយសង្គ្រោះ។ នេះគឺជានិមិត្តរូបនៃការយាងមករបស់កូនចៀមដ៏ពិតប្រាកដនៃព្រះ គឺព្រះយេស៊ូវដែលទ្រង់បានសុគតនៅលើឈើឆ្កាងដើម្បីរំដោះយើងពីអំពើបាប។ ស្ដេចផារ៉ោន និងជនជាតិអេស៊ីព្ទក៏អាចជ្រើសរើសយកការការពារពីព្រះដែរ តែពួកគេមិនបានជឿលើពាក្យដែលម៉ូសេបានប្រាប់ទេ។

**និក្ខមនំ ១២:២៩** ព្រះយេហូវ៉ាទ្រង់ក៏វាយអស់ទាំងកូនច្បងនៅស្រុកអេស៊ីព្ទចាប់តាំងពីបុត្រច្បងរបស់ផារ៉ោនដែលគង់លើបល្ល័ង្ករាជ្យ រហូតដល់កូនច្បងរបស់អ្នកទោសនៅក្នុងគុក ព្រមទាំងកូនច្បងនៃអស់ទាំងសត្វផង។ តែព្រះបានការពារជនជាតិអ៊ីស្រាអែលទាំងអស់វិញ ព្រោះពួកគេបានស្ដាប់បង្គាប់ព្រះ ហើយដាក់សញ្ញាសម្គាល់នៅលើទ្វារផ្ទះរបស់ពួកគេ។ ទីបំផុតស្ដេចផារ៉ោនបានអនុញ្ញាតឲ្យជនជាតិអ៊ីស្រាអែលចេញទៅ ហើយពេលនោះជនជាតិអ៊ីស្រាអែលក៏មានសេរីភាពឡើងវិញ!

## ៦. សំនួរពិភាក្សា

១. តើគ្រោះកាចដែលព្រះបានបញ្ជូនមកដល់ជនជាតិអេស៊ីព្ទមានប៉ុន្មាន? *១០ គ្រោះកាច*

២.តើគ្រោះកាចទី១០នោះជាអ្វី?

*ព្រះយេហូវ៉ាទ្រង់ក៏វាយអស់ទាំងកូនច្បងនៅស្រុកអេស៊ីព្ទចាប់តាំងពីបុត្រច្បងរបស់ផារ៉ោនដែលគង់លើបល្ល័ង្ករាជ្យរហូតដល់កូនច្បងរបស់អ្នកទោសនៅក្នុងគុក ព្រមទាំងកូនច្បងនៃអស់ទាំងសត្វផង*

៣.ហេតុអ្វីបានជាបុត្រច្បងរបស់ផារ៉ោន និងកូនច្បងរបស់ជនជាតិអេស៊ីព្ទត្រូវស្លាប់?

*ពីព្រោះផារ៉ោនរឹងរូសមិនព្រមឲ្យជនជាតិអ៊ីស្រាអែលចាកចេញ*

៤. តើមានអន្ទាក់អ្វីខ្លះនៅក្នុងជីវិតដែលអាចរារាំងយើងបាន?

*អំពើបាប ការព្រួយបារម្ភ ភាពភយ័ខ្លាច ការកុហកឥរិយាបទអាក្រក់។ល។*

តើនរណាជាអ្នកដែលអាចរំដោះយើងឲ្យចេញពីអន្ទាក់នោះបាន? *ព្រះយេស៊ូវ*

## ៧. ល្បែងកំសាន្ត «ព្រះអាចរំដោះយើងបាន»



១. ឲ្យកុមារកាត់ក្រដាសធ្វើខ្សែច្រវាក់ឲ្យបានច្រើនតាមដែរអាចធ្វើទៅបាន (ភ្ជាប់ខ្សែច្រវាក់ក្រដាសរបស់ប្អូនៗជាមួយគ្នា)

២. ជ្រើសរើសអ្នកស្ម័គ្រចិត្តម្នាក់



៣.សូមឱ្យកុមារដែលនៅកន្លែងនិយាយលឺៗនូវឈ្មោះរបស់អ្វីដែលអាចធ្វើឲ្យយើងទាក់ឬរុំយើងបាន ហើយរុំកុមារដែលស្ម័គ្រចិត្តឡើងមកជាមួយក្រដាសច្រវាក់នោះ ស្របពេលដែលកុមារផ្សេងទៀតនៅតែបន្តនិយាយលឺដដែល។

៤.នៅពេលដែលខ្សែច្រវាក់ទាំងមូលត្រូវបានរុំព័ទ្ធជុំវិញកុមារ សូមរំលឹកពួកគេថា មិនថាខ្សែច្រវាក់នៃអំពើបាប ការភ័យខ្លាច ឬការព្រួយបារម្ភខ្លាំងប៉ុណ្ណាក៏ដោយព្រះអាចរំដោះ យើងបាន។

៥.ប្រាប់កុមារដែលស្ម័គ្រចិត្តឲ្យផ្តាច់ច្រវាក់នោះចោលនៅពេលដែលកុមារដទៃទៀតស្រែកថា “ព្រះអាចរំដោះយើងបាន”។

## ៨. ខគម្ពីរចងចាំ យ៉ូហាន ៨:៣៦

**៩. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១០. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*